អន្តរប្រិយ
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ប្រវត្តិចិត្តរបស់មនុស្សសត្វ ។

www.hoksavann.org

ថ្ងៃទី២ កក្កដា ២០១១



ចិត្តប្រែថា ការត្រិះរិះ ឬការសន្សំនូវអារម្មណ៍ ជាធម្មជាតិគ្មានរូបរាងសណ្ឋានទ្រង់ទ្រាយអ្វីទេ ជានាមធម៌ ប៉ុន្តែវាមានភាពពិតជាវិជ្ជមានដែលមនុស្សម្នាក់ៗអាចដឹងបានដោយខ្លួនឯង ។ ចិត្តគ្មានប្រក្រតីពីកំណើតដើមទេ ប៉ុន្តែមានចិត្តដោយសារអាយតនៈខាងក្នុង៦ គឺភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និង មនោ ប៉ះនឹងអាយតនៈខាងក្រៅ៦ គឺរូប សម្លេង ក្លិន រស សម្ផស្ស និងធម្មា (អារម្មណ៍ដែលចិត្តតោង) ដែលហៅថាផស្សាយតនៈ ហើយប្រព្រឹត្តទៅជាខណៈចិត្ត ជាវិថីចិត្ត ទើបកើតជាចិត្តជាវិញ្ញាណឡើង ។ ព្រះសម្ពុទ្ធបានសំដែងនៅក្នុងបដិច្ចសមុប្បាទធម៌ ដែលប្រែថាធម៌កើតឡើងព្រមដោយអាស្រ័យហេតុ ដែលមានហេតុផលទំនាក់ទំនងគ្នា១២យ៉ាងគឺ កាលណាមានអវិជ្ជា នាំឲ្យមានសង្ខារ, សង្ខារនាំឲ្យមានវិញ្ញាណ, វិញ្ញាណនាំឲ្យមាននាមនិងរូប,នាមនិងរូបនាំឲ្យមានអាយតនៈ៦,អាយតនៈ៦នាំឲ្យមានផស្សៈ,ផស្សៈនាំឲ្យមានវេទនា,វេទនានាំឲ្យមានតណ្ហា, តណ្ហានាំឲ្យមានឧបាទាន, ឧបាទាននាំឲ្យមានភព, ភពនាំឲ្យមានជាតិ, ជាតិនាំឲ្យមានជរានិងមរណៈ ។ ដូច្នេះយើងឃើញថា ហេតុផលដែលកើតឡើងជាបន្តគ្នានេះ មានអវិជ្ជា ការពុំដឹងនូវអរិយសច្ច៤ មានទុក្ខសច្ចជាដើម ជាមេហេតុ ។ កាលណាអវិជ្ជារលត់ ហេតុផលបន្តក៏ត្រូវរលត់ដែរ ។ នៅក្នុងហេតុផលនេះ មានពោលអំពីផស្សៈនាំឲ្យកើតវេទនា ពុំឃើញពោលអំពីផស្សៈនាំឲ្យកើតវិញ្ញាណឡើយ ប៉ុន្តែអ្នកសិក្សាគប្បីយល់ថា ផស្សៈពិតជានាំឲ្យកើតវិញ្ញាណ មុននឹងកើតវេទនា តែក្នុងទំនាក់ទំនងនេះ លោកពុំពោលឡើយ ។ ផស្សៈ ការប៉ះគ្នារវាងអាយតនៈខាងក្នុងនិងខាងក្រៅ ទើបកើតវិញ្ញាណមានចក្ខុវិញ្ញាណជាដើម ទើបកើតចេតសិកធម៌ មានវេទនាជាដើម ។ ចំណែកពួករុក្ខជាតិពុំមានអាយតនៈ ទើបពុំអាចបង្កើតជាវិញ្ញាណ ជាចិត្តបាន ។ ក្នុងបញ្ចទ្វារមានចក្ខុទ្វារជាដើម មានខណៈចិត្ត១៧ និងវិថីចិត្ត៧ ។ ខណៈចិត្ត១៧នោះគឺ ១- ភវង្គៈ កាត់ជាពីរបទគឺ ភវៈនិងអង្គៈ ។ អង្គៈប្រែថា ប្រដាប់, ភវៈប្រែថាចេតនា រួមពាក្យទាំងពីរប្រែថា ប្រដាប់សំរាប់បង្កើតចេតនា ។ បានសេចក្តីថា ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ មានសរសៃប្រសាទនៅក្នុងនោះ អាចបង្កើតវិញ្ញាណបង្កើតចិត្ត បើកាលណាមានអាយតនៈទាំង៦ខាងក្រៅមកប៉ះ ។ បើគ្មានអាយតនៈខាងក្រៅណាមួយមកប៉ះទេ វានៅជាភវង្គធម្មតាពុំទាន់កើតចិត្តទេ ។ ដូចជាប្រដាប់ថតរូប បើគេពុំទាន់យកទៅថតទេ វានៅជាប្រដាប់ធម្មតា យ៉ាងណាមិញ ប្រដាប់ថតរូបដូចជាភវង្គ, រូបខាងក្រៅដូចជាអាយតនៈខាងក្រៅ ។ ២- ភវង្គចលនៈ ប្រែថា ញ័រភវង្គ នេះពេលអារម្មណ៍មកប៉ះ ។ ៣- ភវង្គុប្បច្ឆេទ ប្រែថាដាច់ខ្សែភវង្គ គឺខណៈនេះចេញផុតពីភវង្គហើយ ។ ៤- បញ្ចទ្វារាវជ្ជនៈ ប្រែថាការនឹករកអារម្មណ៍ក្នុងទ្វារទាំង៥មានចក្ខុទ្វារជាដើម ។ ៥- បញ្ចវិញ្ញាណ ប្រែថាវិញ្ញាណ៥ សេចក្តីថា ខណៈចិត្តទី៥នេះកើតវិញ្ញាណការដឹងហើយ ។ ៦-សម្បដិច្ឆន្នៈ ការទទួលអារម្មណ៍នោះ ។ ៧- សន្តីរណៈ ការពិចារណានូវអារម្មណ៍នោះ ។ ៨- វោដ្ឋវនៈ កត់ត្រានូវអារម្មណ៍នោះ ត្រង់វោដ្ឋវនៈនេះ ជាតួសញ្ញាចាំបាននូវអារម្មណ៍ដែលបានប៉ះនោះ ។ បើខណៈចិត្តកើតឡើងតែត្រឹមនេះ មិនកើតបន្តទៀតទេ ចិត្តធ្លាក់កាន់ភវង្គវិញ លោកហៅថាអហេតុកចិត្ត ប្រែថាចិត្តគ្មានហេតុ ។ ៩- ជវន ប្រែថាចិត្តស្ទុះទៅ គឺចិត្តត្រេកអរ ឬប្រទូស្សចំពោះអារម្មណ៍នោះ ។ ត្រង់ជវននេះហើយ ចាត់ជាសហេតុកចិត្ត ប្រែថាចិត្តប្រកបដោយហេតុ ។ ហេតុនេះមាន៦គឺ កុសល៣គឺ លោភោ ទោសោ មោហោ ។ ជវនកើតឡើង៧ខណៈក៏រលត់ទៅ ហើយខណៈចិត្តកើតឡើងត្រឹមជវននេះ ហើយចាត់ជាបុណ្យជាបាប ។ ១០- តទាលម្ពណៈ ប្រែថាតោងនូវអារម្មណ៍នោះ ។ បានសេចក្តីថា បន្ទាប់ពីជវនកន្លងផុតទៅ ចិត្តនៅតោងអារម្មណ៍នោះ២ខណៈ ទើបរលត់ទៅ ។ ខណៈចិត្តរាប់ពីភវង្គៈដល់តទាលម្ពណៈ ត្រង់ជវនមាន៧ តទាលម្ពណៈមាន២ រួមជា១៧ ។ ចំណែកវិថីចិត្តរាប់ពីបញ្ចទ្វារាវជ្ជនៈ ដល់តទាលម្ពណៈមាន៧ ។ ផ្នែកមនោទ្វារាវជ្ជនៈវិញ មានវិថីចិត្តតែ៣គឺ មនោទ្វារាវជ្ជនៈ១ ជវន៧ និងតទាលម្ពណៈ២ ។

តាមការរៀបរាប់មកនេះបញ្ជាក់ថា ចិត្តវិញ្ញាណពុំមានទេ បើពុំមានផស្សៈ ការប៉ះរវាងអាយតនៈខាងក្នុង៦ និងខាងក្រៅ៦ ។ ឧទាហរណ៍ការកើតវិញ្ញាណតាមភ្នែក គឺចក្ខុធាតុ ប៉ះនិងរូបធាតុ កើតចក្ខុវិញ្ញាណធាតុ, មនោធាតុប៉ះនិងធម្មធាតុ (អារម្មណ៍តាមមនោទ្វារ) កើតមនោវិញ្ញាណធាតុ ។ នេះគឺជាការផ្សំគ្នារវាងរូបធម៌ ទើបកើតនាមធម៌ ។ ចិត្តវិញ្ញាណជាអនត្តា ព្រោះកើតរលត់គ្រប់ខណៈហៅថាខណិកមរណៈ ។ ត្រង់វិញ្ញាណជាអនត្តា ពុំមានខ្លួននេះហើយ ដែលព្រះពុទ្ធបដិសេធសាសនាព្រាហ្មណ៍ដែលថា រូបស្លាប់ទៅសាសនានេះហៅថាអាត្ម័ន ឬអត្តាមិនស្លាប់ឡើយ ។៚

*                    *

*